# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែមេសា ឆ្នាំ២០២០

នៅក្នុងខែមេសា ឆ្នាំ២០២០នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ:

**១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖**

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០១លើក

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ ៖**

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០១លើក។

**ខ-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ និងអន្តរជាតិ ៖**

-ទទួលសារតាំងពីឯកឧត្តម Ermenegildo Kupa LopesGentil ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ

-អនុញ្ញាតជូនឯកឧត្តម Dmitry Tsvetkov ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសហព័ន្ធរុស្ស៊ី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា។

**គ-សកម្មភាពចូលរួមពិធីផ្សេងៗ ៖**

-អញ្ជើញចូលរួមដង្ហែព្រះរាជដំណើរ**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ស្តេចយាងព្យាបាលព្រះរាជសុខភាព នៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

**ឃ-សកម្មភាពចុះមូលដ្ឋាន ៖**

-អញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខមន្ត្រី និងអាជ្ញាធរសង្កាត់



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum sarith@camnet.com.kh

ក្រាំងធ្នង់ ក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ

-អញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខមន្ត្រី និងអាជ្ញាធរសង្កាត់សាក់សំពៅ ក្នុងខណ្ឌដង្កោ រាជធានីភ្នំពេញ។

**ង-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-ចុះហត្ថលេខាលើព្រះរាជក្រមចំនួន០៣ច្បាប់

-ចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន៥៧ច្បាប់

-ទទួលព្រះរាជសារព្រះរាជទានសិទ្ធិចំនួន៤៥ច្បាប់ ទទួលសំណើពីរាជរដ្ឋាភិបាលចំនួន៤៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២០ច្បាប់។

**១.២ ឯកឧត្តម ស៊ឹម កា អនុប្រធានទី១ព្រឹទ្ធសភា បាន :**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០១លើក។

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ៖**

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០៤លើក និងកិច្ចប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ និងកិច្ចប្រជុំពេញអង្គ នីតិកាលទី៤ ចំនួន០៣លើក

-អញ្ជើញចូលរួមប្រជុំក្រុមសមាជិករដ្ឋសភា-ព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមប្រជុំផ្ទៃក្នុងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនា-ភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា។

**ខ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៥៣ច្បាប់។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន :**

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ៖**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០៥លើក និងកិច្ចប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ និងកិច្ចប្រជុំពេញអង្គ នីតិកាលទី៤ ចំនួន០៣លើក។

**ខ-សកម្មភាពចុះមូលដ្ឋាន៖**

-អញ្ជើញនាំយកបច្ច័យចំនួន១០,២០០ដុល្លារ ប្រគេនព្រះចៅអធិការវត្តប្រាំបីមុំ

សម្រាប់កសាងដងទង់ព្រះវិហារ នៅវត្តប្រាំបីមុំ ដែលស្ថិតនៅក្នុងឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ

-អញ្ជើញជួបសំណេះសំណាលជាមួយអាជ្ញាធរឃុំ សង្កាត់ នៅឃុំអូរសោម ខេត្តពោធិ៍សាត់។

**គ-សកម្មភាពចូលរួមពិធីផ្សេងៗ៖**

-អញ្ជើញចូលរួមក្នុងពិធីបុណ្យ និងបញ្ចុះសពឧបាសិកា **លឹម គឹមមួយ** នៅវត្តប្រាំបីមុំ ដែលស្ថិតនៅក្នុងឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ។

**ឃ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ៖**

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០៤ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១០ច្បាប់។

**២.សម័យប្រជុំគណៈកម្មាធិការអេចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០៥លើក:**

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានបើកកិច្ចប្រជុំចំនួន០៥លើក ដែលមានរបៀបវារៈដូចខាងក្រោម:

១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន **រ៉ូយាល់គ្រុប អ៊ិនវេសម៉ិនគ្រុប ឯ.ក** សម្រាប់គម្រោងវិនិយោគសាងសង់រោងចក្រអគ្គិសនីដុតធ្យូងថ្មអានុភាព ៧០០ មេហ្គាវ៉ាត់ ខេត្តកោះកុង

២-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន **ហាន សេង ខូល ម៉ាញ** សម្រាប់គម្រោងវិនិយោគសាងសង់រោងចក្រអគ្គិសនីដុតធ្យូងថ្មអានុភាព ២៦៥ មេហ្គាវ៉ាត់ ខេត្តបន្ទាយមានជ័យ

៣-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន **ហាន សេង ខូល ម៉ាញ** សម្រាប់គម្រោងវិនិយោគសាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនីតង់ស្យុង២៣០ គីឡូវ៉ុល

តភ្ជាប់ពីរោងចក្រអគ្គិសនីដុតធ្យូងថ្ម ខេត្តបន្ទាយមានជ័យ មកអនុស្ថានីយ៍សៀមរាបខាងកើត

៤-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការនីតិកម្ម និងយុត្តិធម៌ សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

៥-ពិនិត្យ និងសម្រេចលើរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៤ និងលើកទី៥ នីតិកាលទី៤។

**៣.សម័យប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០២លើក និងពេញអង្គចំនួន០១លើក:**

ប្រជុំព្រឹទ្ធសភាជាវិសាមញ្ញចំនួន០២លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើ៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន **រ៉ូយាល់គ្រុប អ៊ិនវេសម៉ិន គ្រុប ឯ.ក** សម្រាប់គម្រោងវិនិយោគសាងសង់រោងចក្រអគ្គិសនីដុតធ្យូងថ្ម អានុភាព៧០០មេហ្គាវ៉ាត់ ខេត្តកោះកុង

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន **ហាន សេង ខូល ម៉ាញ** សម្រាប់គម្រោងវិនិយោគសាងសង់រោងចក្រអគ្គិសនីដុតធ្យូងថ្មអានុភាព២៦៥ មេហ្គាវ៉ាត់ ខេត្តបន្ទាយមានជ័យ

៣-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន **ហាន សេង ខូល ម៉ាញ** សម្រាប់គម្រោងវិនិយោគសាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនីតង់ស្យុង២៣០គីឡូវ៉ុល តភ្ជាប់ពីរោងចក្រអគ្គិសនីដុតធ្យូងថ្ម ខេត្តបន្ទាយមានជ័យ មកអនុស្ថានីយ៍សៀមរាបខាងកើត

៤-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

៥-ស្តាប់របាយការណ៍ស្តីពីលទ្ធផល និងសកម្មភាពការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី៤ និងលើកទី៥ នីតិកាលទី៤។

**៤-សកម្មភាពប្រយុទ្ធនឹងជំងឺកូវីដ១៩**

ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបរិច្ចាគថវិកាផ្ទាល់ខ្លួន ប្រាក់បៀវត្សផ្ទាល់ខ្លួន គ្រឿងឧបភោគ បរិភោគ

និងសម្ភារៈការពារ ព្រមទាំងបានចុះអប់រំ ផ្សព្វផ្សាយអំពីវិធានការការពារ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ជូនប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា។

**៥.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា :**

ក្នុងខែមេសានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម:

**៥.១ មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-អញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តម**បណ្ឌិត ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ដើម្បីឈ្វេងយល់អំពីការវិវត្តរីកចម្រើនថ្មីៗ បញ្ហាប្រឈម និងស្ដាប់របាយការណ៍លទ្ធផលការងារសម្រេចបានឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០។

**៥.២ មុខងារតំណាង**

-បានទទួលពាក្យបណ្ដឹងបានចំនួន០២ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយបានចំនួន០៦ករណី ធ្វើកំណត់បង្ហាញពាក្យបណ្ដឹងបានចំនួន០៦ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធបានចំនួន០២ករណី ឆ្លើយតបទៅម្ចាស់បណ្ដឹងបានចំនួន០៦ករណី និងទទួលឯកសារពាក្យបណ្ដឹងដែលក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ដើម្បីជូនជ្រាបបានចំនួន០១ករណី។

-ប្រជុំពិនិត្យ និងពិភាក្សាលើ " ការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយ សម្រាប់អនុវត្តច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ លើកទី២"

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ បានប្រជុំពិភាក្សាអំពីការងារចាំបាច់មួយដើម្បីរួមចំណែកក្នុងការបង្ការ និងទប់ស្កាត់នៃការរីករាលដាលជំងឺកូវីដ១៩ នៅមណ្ឌលភូមិភាគទី៦ ខេត្តព្រៃវែង និងខេត្តស្វាយរៀង

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះទៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តក្រុងចំនួន១៤៩លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងផ្សព្វផ្សាយវិធីបង្ការ និងទប់ស្កាត់ជំងឺកូវីដ

១៩ ដល់ប្រជាពលរដ្ឋ និងពលករមកពីបរទេស ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការផ្សេងៗចំនួន០៨លើក។

ថ្ងៃសុក្រ ២កើត៩ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២០

ជ.ប្រធានស្ដីទីព្រឹទ្ធសភា

អនុប្រធានទី២

ទេព ងន

ចម្លងជូន
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ